# បទបញ្ជានៃអាមម៉ូនីញ៉ូម ណៃត្រេត (MMONIUM NITRATE): សន្លឹកពត៌មានសង្ខេបសំរាប់អ្នកផលិតវត្ថុធាតុដើម

## ប្រព័ន្ធអាជ្ញាប័ណ្ណថ្មី

អាមម៉ូនីញ៉ូម ណៃត្រេតអាចគេយកទៅប្រើក្នុងគ្រឿងផ្ទុះ ហើយមានប្រវត្តិប្រើដោយពួកភេរវជន។ យោងទៅតាមទិសដៅសន្តិសុខជាតិ គ្រប់ទាំងរដ្ឋាភិបាលអូស្ត្រាលីបានព្រមព្រៀងគ្នានៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៤ ទៅនឹងដំណោះស្រាយជាតិលើកការហាមឃាត់ដែលប៉ះពាល់ដល់សន្តិសុខនៃការប្រើអាមម៉ូនីញ៉ូម ណៃត្រេត (SSAN) ឯទៀតក្រៅពីអ្នកប្រើដែល ត្រូវបានអនុញ្ញាតក្នុងលក្ខណះពិសេស។

ការព្រមព្រៀងគ្នានេះបានហុចមកនូវលទ្ធផលក្នុងការរៀបចំក្នុងរដ្ឋ និងដែនដីនីមួយៗនូវប្រព័ន្ធអាជ្ញាប័ណ្ណសំរាប់ការប្រើការ តម្កល់ទុក និងការដឹកជញ្ជូននៃ SSAN។ ប្រព័ន្ធអាជ្ញាប័ណ្ណនឹងធ្វើឲ្យជាក់លាក់ថា SSAN អាចនឹងមានសិទ្ធិប្រើដោយបុគ្គលណាដែលនឹងតម្កល់ទុក ហើយប្រើប្រាស់វាដោយឥតគ្រោះថ្នាក់ និងដោយមានសន្តិសុខប៉ុណ្ណោះ។

## តើអ្វីខ្លះដែលកំពុងត្រូវបានដាក់ចូលក្នុងបទបញ្ជា?

“SSAN” រាប់បញ្ចូលទាំងអាមម៉ូនីញ៉ូម ណៃត្រេត (ពោលគឺ១០០ភាគរយអាមម៉ូនីញ៉ូម ណៃត្រេតសុទ្ធ) អាមម៉ូនីញ៉ូម ណៃត្រេតជាតិរាវ និងអាមម៉ូនីញ៉ូម ណៃត្រេតធាតុល្បាយ ដែលមានអាមម៉ូនីញ៉ូម ណៃត្រេតលើសពី៤៥ភាគរយ ដោយមិនរាប់បញ្ចូលជាតិរលាយ និងគ្រឿងផ្ទុះថ្នាក់ទី១ទេ។ នេះរាប់បញ្ចូលទាំងសារធាតុទាំងឡាយដូចជាកាលស្យូម អាមម៉ូនីញ៉ូម ណៃត្រេត (calcium ammonium nitrate) និងទំនិញមានគ្រោះថ្នាក់ទាំងឡាយដែលមានចុះលេខអង្គការសហប្រជាជាតិ (UN) 1942, 2067, 2068, 2069, 2070, 2071, 2072, 3375 និង 3139 ពេលណាអនុវត្ត។ ជីគីមីដែលមានអាមម៉ូនីញ៉ូម ណៃត្រេតលើសពី៤៥ភាគរយ នោះនឹងត្រូវបានគេដាក់ចូលក្នុងបទបញ្ជា។ សូមយោងទៅតារាងខាងក្រោមនេះ។

## ជីគីមី SSAN

តារាងទី១ - អាមម៉ូនីញ៉ូម ណៃត្រេត (AN)

តារាងទី២ - កាល់ស្យូម អាមម៉ូនីញ៉ូម ណៃត្រេត (CAN)

តារាងទី៣ - ល្បាយដែលមាន AN និង CAN

**តារាងទី១**

| ល្បាយអាមម៉ូនីញ៉ូម ណៃត្រេត | |
|---|---|
| **ឈ្មោះក្រុមហ៊ុន Grow Force** | **ភាគរយ AN** |
| Nitra Force 601 | 55 |
| Nitra Force 605 | 65 |
| Nitra Force 606 | 60 |
| Nitra Force 608 | 60 |
| Nitra Force 609 | 63 |
| Nitra Force 615 | 65 |
| Nitra Force 616 | 60 |
| Nitra Force 620 | 60 |
| Nitra Force 635 | 53 |
| Nitra Force 640 | 60 |
| Nitra Force 641 | 60 |
| Nitra Force 642 | 50 |
| Nitra Force 643 | 59 |
| Nitra Force 654 | 65 |
| Nitra Force 17-0-21 | 50 |
| Nitra Force 19-1-8 | 55 |
| Nitra Force 19-8-10 | 46 |
| Nitra Force 20-0-15+Mg | 59 |
| Nitra Force 20-0-16-7 | 60 |
| Nitra Force 20-0-20 | 60 |
| Nitra Force 21-3-15 | 55 |
| Nitra Force 22-3-8 | 61 |
| Nitra Force 22-3-14 | 60 |
| Nitra Force 23-6-5 | 50 |
| Nitra Force 27-9-0 | 54 |

**តារាងទី២**

| ឈ្មោះក្រុមហ៊ុន Incitec Pivot | ភាគរយ AN |
|---|---|
| Accelerator | 50 |
| Aftergraze | 61 |
| Aftermow | 61 |
| Anchor Plus | 51 |
| Bumpabunch | 60 |
| Greengraze | 50 |
| Hortram K | 59 |
| Hortram K (Fe) | 57 |
| Nitram 135 | 53 |
| Nitram 140 | 60 |
| Nitram 140(S) | 60 |
| Nitram 150 | 55 |
| Nitram 160 | 63 |
| Nitram 50/50 | 60 |
| Nitram 50/50(S) | 60 |
| Nitram 700 | 65 |
| Nitram Hi-N Ratooner | 60 |
| Nitram Hi-P Ratooner | 50 |
| Nitram K | 65 |
| Nitram K(S) | 65 |
| Nitram Ratooner | 65 |
| Nitram SOP | 65 |
| Prodress | 55 |
| Speed | 54 |
| Swift | 46 |

**តារាងទី៣**

| ល្បាយកាល់ស្យូម អាមម៉ូនីញ៉ូម ណៃត្រេត | |
|---|---|
| **ឈ្មោះក្រុមហ៊ុន Incitec Pivot** | **ភាគរយ AN** |
| Cal-Am 135 | 64 |
| Cal-Am 140 | 50 |
| Cal-Am 150 | 48 |
| Cal-Am 50/50 | 52 |
| Cal-Am K(S) | 52 |
| Cal-Am Nitra K | 59 |
| Cal-Am Nitra King | 59 |
| Green 1 | 45 |
| Green 2 | 54 |
| Green 3 | 68 |
| Green 4 | 55 |
| Green 5 | 52 |
| Nitrogreen M 20 | 54 |
| Nitrogreen M 20(S) | 45 |
| Nitrogreen M 35 | 60 |
| Nitrogreen M 40 | 52 |
| Nitrogreen M 40(S) | 48 |
| Nitrogreen M 50 | 48 |
| Nitrogreen M 50/50 | 52 |
| Nitrogreen M K(S) | 52 |
| មានតែល្បាយដែលមានច្រើនជាង CAN ៥៦ភាគរយប៉ុណ្ណោះដែលស្មើនឹង AN ៤៥ភាគរយ ដែលត្រូវបានចុះ។ | |

បញ្ជីទាំងនេះមិនទាន់ច្បាស់លាស់នៅឡើយ មានចុះពត៌មានដែលផ្តល់ឲ្យដោយសហព័ន្ធឧស្សាហកម្មជីគីមីអូស្ត្រាលី (FIFA) ដែលមានជំនួយពី Incitec Pivot Limited, Grow Force, Hi-Fert និង Summit ព្រមទាំងក្រុមហ៊ុនតូចៗខ្លះទៀតផងដែរ។

## ហេតុដូចម្តេចបានជាមិនហាមឃាត់ SSAN?

ឧស្សាហកម្មជីកយករ៉ែត្រូវពឹងពាក់ទៅលើអាមម៉ូនីញ៉ូម ណៃត្រេត ហើយការហាមឃាត់ទាំងស្រុងមិនមែនជាជំរើសដែលសមហេតុផលទេ។ ក្នុងពេលដែលរដ្ឋាភិបាលបានគិតគូរហាមឃាត់លើការប្រើខាងកសិកម្មនោះ មតិភាគច្រើនបានសំរេចនូវការឆ្លើយតបដ៏សមរម្យ និងទៅតាមសមាមាត្រគឺអនុញ្ញាតឲ្យអាមម៉ូនីញ៉ូម ណៃត្រេតនៅមានបន្តទៅទៀតសំរាប់អ្នកប្រើដែលស្របច្បាប់ដែលមិនជាប់ទាក់ទិនក្នុងរឿងសន្តិសុខ ហើយដែលគេនឹងតម្កល់ទុក ហើយដឹកជញ្ជូនវាប្រកបដោយសន្តិសុខ។

**ការកត់សម្គាល់: SSAN នឹងត្រូវបានហាមឃាត់សំរាប់គោលបំណងខាងកសិកម្មនៅក្នុងរដ្ឋ Tasmania ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៥។**

### តើមានជីគីមីដទៃទៀតត្រូវបានចុះក្នុងបទបញ្ញាឬទេ?

បទបញ្ញានៃ SSAN គឺជាជំហានទីមួយក្នុងការពិនិត្យសើរើយ៉ាងល្អិតល្អន់នូវសម្ភារៈប្រកបទៅដោយគ្រោះថ្នាក់ ដែលក្នុងពេលបច្ចុប្បន្ននេះត្រូវបានគ្រប់គ្រងដោយរដ្ឋាភិបាលអូស្ត្រាលី។ ជាតិគីមី សារធាតុបង្កើតជាតិពុលសំរាប់ធ្វើអាវុធ និងសម្ភារៈខាងវិទ្យុសកម្មឯទៀត ក៏កំពុងត្រូវបានចាត់ទុកថាជាផ្នែកនៃការសើរើពិនិត្យឡើងវិញនេះដែរ។ សារធាតុដទៃទៀតខ្លះអាចនឹងសំគាល់ឃើញ សំរាប់បទបញ្ញារដ្ឋាភិបាលនៅក្នុងដំណើរការនេះ។

### តើនរណានឹងតម្រូវឲ្យមានអាជ្ញាប័ណ្ណដើម្បីប្រើ SSAN?

ប្រព័ន្ធច្បាប់តុលាការក្នុងរដ្ឋ និងដែនដីនីមួយៗបានប្ដេជ្ញាដាក់បញ្ចូលប្រព័ន្ធអាជ្ញាប័ណ្ណដែលនឹងអនុវត្តលើការនាំចេញ ការនាំចូល ការតម្កល់ទុក ការដឹកជញ្ជូន ការលក់ដូរ ការផ្គត់ផ្គង់ ការទិញ ការទទួលយក ការប្រើ និងការបោះចោលនៃ SSAN។

អាជ្ញាប័ណ្ណនឹងមានសំរាប់តែ:

- អស់អ្នកដែលអាចបង្ហាញឲ្យឃើញច្បាស់នូវសេចក្ដីត្រូវការស្របច្បាប់សំរាប់ SSAN;
- អស់អ្នកដែលនឹងដឹកជញ្ជូន ហើយតម្កល់ទុកប្រកបដោយសន្តិសុខ (នឹងមានការតម្រូវឲ្យដាក់ស្នើគំរោងសន្តិសុខសំរាប់កន្លែងតម្កល់ទុក) និង
- អស់អ្នកដែលមិនជាប់ទាក់ទិនក្នុងរឿងសន្តិសុខ (គ្រប់ទាំងអ្នកដាក់ពាក្យសុំនឹងតម្រូវឲ្យឆ្លងកាត់ការឆែកពិនិត្យពីប៉ូលិស និង ASIO)។

លោកអ្នកប្រហែលជាមិនត្រូវការអាជ្ញាប័ណ្ណដោយឡែកឡើយ សំរាប់សកម្មភាពនីមួយៗដែលលោកអ្នកទទួលយល់ព្រមធ្វើជាមួយនឹង SSAN។ អាជ្ញាប័ណ្ណអាចត្រូវបានចេញឲ្យដើម្បីគ្របដណ្ដប់ទៅលើសសកម្មភាពលើសពីមួយ ហើយលោកអ្នកគួរតែពិគ្រោះជាមួយនឹងអាជ្ញាធរធ្វើបទបញ្ញានៅក្នុង រដ្ឋ ឬដែនដីរបស់លោកអ្នក ដោយមានរបាយការណ៍ល្អិតល្អន់អំពីសកម្មភាពដែលលោកអ្នកនឹងទទួលយល់ព្រមធ្វើ (សូមមើលខាងក្រោមនេះ)។

ប្រសិនបើអ្នកត្រូវការប្រើ SSAN នៅក្នុងរដ្ឋ ឬដែនដីលើសពីមួយ លោកអ្នកនឹងត្រូវការអាជ្ញាប័ណ្ណនៅក្នុងរដ្ឋ និងដែនដីនីមួយៗ។

### ហេតុដូចម្ដេចបានជាអ្នកប្រើ SSAN នឹងត្រូវស្ថិតនៅក្រោមការឆែកពិនិត្យពីប៉ូលិស និងការឆែកពិនិត្យខាងសន្តិសុខ?

រដ្ឋាភិបាលត្រូវឲ្យដឹងច្បាស់ថាអ្នកប្រើទាំងឡាយមិនជាប់ទាក់ទិនក្នុងរឿងសន្តិសុខ។ ការឆែកពិនិត្យទាំងនេះមិនមែនប្លែកខុសពីធម្មតាឡើយ ហើយជាផ្នែកទម្លាប់នៃការបោសសំអាតជនណាម្នាក់ចេញពីគោលបំណងជាក់លាក់ណាមួយ។

### ប្រសិនបើខ្ញុំមិនបានជោគជ័យនៅក្នុងការឆែកពិនិត្យខាងសន្តិសុខ តើខ្ញុំអាចប្ដឹងតវ៉ាបានឬទេ?

បាន។ នរណាម្នាក់ដែលបានជាប់ការស្ទង់ប៉ាន់សន្តិសុខ ឬមិនបានជាប់ការស្ទង់ប៉ាន់ សន្តិសុខនឹងត្រូវគេផ្ដល់ដំណឹងអំពីមូលហេតុ ហើយអាចប្ដឹងតវ៉ាទៅតុលាការប្ដឹងតវ៉ាកិច្ចការរដ្ឋបាល (Administrative Appeals Tribunal)។

### តើខ្ញុំទទួលអាជ្ញាប័ណ្ណដោយរបៀបណា?

លោកអ្នកនឹងបានទទួលពាក្យសុំអាជ្ញាប័ណ្ណ ហើយត្រូវអាជ្ញាធរចេញបទបញ្ញាពីរដ្ឋ ឬដែនដីនីមួយៗចេញអាជ្ញាប័ណ្ណឲ្យ។ ដើម្បីរកមើលអាជ្ញាធរធ្វើបទបញ្ញានៅក្នុងរដ្ឋ ឬដែនដីរបស់លោកអ្នកសូមយោងទៅតារាងខាងក្រោមនេះ។

### អាជ្ញាធរចេញបទបញ្ញា

| |
|---|
| **NSW** WorkCover Assistance Service<br>(កិច្ចបំរើជំនួយ វើកខាវវេ រដ្ឋញូវសៅវែល))<br>ទូរស័ព្ទ: 131 050<br>អ៊ីម៉េល: contact@workcover.nsw.gov.au |
| **VIC** Dangerous Goods Unit WorkSafe Victoria<br>(ក្រុមត្រួតពិនត្យទំនិញមានគ្រោះថ្នាក់ វើកសេវ រដ្ឋវិចតូរីយ៉ា)<br>ទូរស័ព្ទ: 03 9641 1555<br>អ៊ីម៉េល: info@workcover.vic.gov.au |
| **QLD** Chief Inspector of Explosives<br>Department of Natural Resources and Mines<br>(ចៅហ្វាយត្រួតពិនិត្យគ្រឿងផ្ទុះ ក្រសួងធនធានធម្មជាតិ និងរ៉ែ)<br>ទូរស័ព្ទ:: 32371386 ទូរសារ: 32354395<br>អ៊ីម៉េល: explosives@nrm.qld.gov.au<br>គេហទំព័រ: nrm.qld.gov.au/mines/explosives |
| **WA** Safety and Health Division<br>Department of Industry and Resources<br>(សាខានិរភ័យ និងសន្តិសុខ រដ្ឋអូស្ត្រាលីខាងលិច)<br>(ក្រសួងឧស្សាហកម្ម និងធនធានដើម)<br>មណ្ឌលទទួលទូរស័ព្ទ:: 08 9222 3413<br>មណ្ឌលទទួលទូរសារ:: 08 9222 3525<br>អ៊ីម៉េល: edg@doir.wa.gov.au |
| **SA** Workplace Services<br>(កិច្ចបំរើ ទីកន្លែងធ្វើការ រដ្ឋអូស្ត្រាលីខាងត្បូង)<br>Department for Administrative and Information Services<br>(កិច្ចបំរើក្រសួងរដ្ឋបាល និងពត៌មាន)<br>កិច្ចបំរើផ្ដល់ពត៌មាន: 1300 365 255<br>ទូរស័ព្ទ: 08 8303 0400 ទូរសារ: 08 8303 0423<br>គេហទំព័រ: www.Eric.sa.gov.au |
| **TAS** Helpline (Workplace Standards Tasmania)<br>(ខ្នាតគំរូទីកន្លែងធ្វើការ រដ្ឋ Tasmania)<br>PO Box 56, Rosny Park TAS 7018<br>ទូរស័ព្ទ: 1300 366 322 (ថ្លៃទូរស័ព្ទក្នុងតំបន់)<br>ទូរស័ព្ទ: 03 6233 7657 (នៅក្រៅរដ្ឋ Tasmania)<br>ទូរសារ: 03 6233 8338<br>គេហទំព័រ: www.wst.tas.gov.au |
| **NT** NTWorkSafe (វើកសេហ្វ NT)<br>ទូរស័ព្ទ: 1800 019 115<br>អ៊ីម៉េល: ntworksafe.deet@nt.gov.au<br>គេហទំព័រ: www.worksafe.nt.gov.au |
| **ACT** ACT WorkCover (វើកខាវវើ ដែនដីអូស្ត្រាលី)<br>Dangerous Substances, Gas & Plant Unit<br>(ក្រុមត្រួតពិនិត្យសារធាតុមានគ្រោះថ្នាក់ ឧស្ម័ន និងរោងចក្រ)<br>PO Box 224, CIVIC SQUARE ACT 2608<br>ទូរស័ព្ទ: 02 6205 0200 ទូរសារ: 02 6205 0336<br>Email: workcover@act.gov.au |

**ការកត់សម្គាល់: កិច្ចបំរើបកប្រែភាសាសរសេរ និងនិយាយ ឬឱវាទស្តីអំពីការផ្តល់នូវកិច្ចបំរើបែបនេះ អាចរកបានតាមរយៈអាជ្ញាធរធ្វើបទបញ្ជានៅក្នុងរដ្ឋ ឬដែនដីនីមួយៗ។**

**តើប្រព័ន្ធអាជ្ញាប័ណ្ណនឹងចាប់ផ្តើមនៅពេលណា?**
ប្រព័ន្ធអាជ្ញាប័ណ្ណកំពុងតែមានដំណើរការនៅក្នុងរដ្ឋឃ្វីនស្លែន ហើយមិនយូរប៉ុន្មាននឹងចាប់ផ្តើមនៅក្នុងរដ្ឋ និងដែនដីនីមួយៗ។ ថ្ងៃទីដែលទំនងនឹងត្រូវដាក់ពាក្យសុំនៅក្នុងរដ្ឋ និងដែនដីឯទៀតគឺ:

NT ខែវិច្ឆិកា ឆ្នាំ២០០៤
ACT ខែមេសា ឆ្នាំ២០០៥
VIC ខែកក្កដា ឆ្នាំ២០០៥
WA ខែសីហា ឆ្នាំ២០០៥
NSW ខែកក្កដា ឆ្នាំ២០០៥
SA ពាក់កណ្តាលឆ្នាំ២០០៥
TAS ខែមិថុនា ឆ្នាំ២០០៥ (សំរាប់ការប្រើផ្សេងពីកសិកម្ម)

**តើអាជ្ញាប័ណ្ណនេះនឹងត្រូវអស់តម្លៃប៉ុន្មាន?**
តម្លៃ និងរយៈពេលនៃការចេញអាជ្ញាប័ណ្ណនឹងប្រែប្រួលបន្តិចបន្តួចពីរដ្ឋមួយទៅរដ្ឋមួយ។ លោកអ្នកត្រូវឆែកមើលជាមួយនឹងអាជ្ញាធរធ្វើបទបញ្ជាដែលទាក់ទិននោះ។

**តើខ្ញុំនឹងត្រូវការផ្តល់អ្វីខ្លះជាមួយនឹងការដាក់ពាក្យសុំអាជ្ញាប័ណ្ណរបស់ខ្ញុំ?**
គ្រប់ទាំងការដាក់ពាក្យសុំអាជ្ញាប័ណ្ណដើម្បីប្រើ SSAN ត្រូវតែមានភ្ជាប់មកជាមួយនូវគំរោងការសន្តិសុខ ដែលនឹងតម្រូវឲ្យមានការយល់ព្រមពីអាជ្ញាធរធ្វើបទបញ្ជា។ គំរោងការសន្តិសុខនោះនឹងផ្តល់នូវពត៌មានទៅអាជ្ញាធរធ្វើបទបញ្ជា អំពីរបៀបដែលលោកអ្នកនឹងបំពេញទៅលើសេចក្តីតម្រូវលើផ្នែកសន្តិសុខ។ <u>សេចក្តីតម្រូវយ៉ាងតិចបំផុតលើផ្នែកសន្តិសុខ</u> ដើម្បីទទួលយកអាជ្ញាប័ណ្ណនឹងមានខុសគ្នា គឺអាស្រ័យទៅលើសកម្មភាពដែលបំរុងនឹងធ្វើនៅក្រោមអាជ្ញាប័ណ្ណនោះ (ពោលគឺកាប្រើខាងកសិកម្ម ការដឹកជញ្ជូន ការតម្កល់ទុក)។

គំរោងការសន្តិសុខនឹងមានបីផ្នែកដែលសំខាន់:

1. ការគ្រប់គ្រងបុគ្គលិក (ដែលនៅក្នុងនោះ គ្រប់ទាំងបុគ្គលនៅនឹងទីកន្លែងដែលនឹងប្រើ SSAN នឹងត្រូវបានរាយឈ្មោះនៅក្នុងបញ្ជី);
2. សន្តិសុខនៅទីកន្លែង (កត់ចុះនូវពត៌មានល្អិតល្អន់អំពីគ្រឿងប្រដាប់ប្រើតម្កល់ទុកដែលមានសន្តិសុខ); និង
3. ទម្រង់ដំណើរការ (ស្តីពីការគ្រប់គ្រងដល់ការប្រើ ដើម្បីធ្វើឲ្យមានសន្តិសុខដល់ការតម្កល់ទុក និងរក្សាកំណត់ហេតុ និងទម្រង់ដំណើរការបញ្ជីសារពីភ័ណ្ឌ)។

**សំរាប់អ្នកប្រើ:** <u>សេចក្តីតម្រូវយ៉ាងតិចបំផុតលើផ្នែកសន្តិសុខ</u> គឺ:

- ត្រូវតម្កល់ទុក SSAN នៅក្នុងគ្រឿងប្រដាប់ប្រើ ឬធុងដែលមានចាក់សោរជាប់ ឬដាក់នៅក្រោមការឃ្លាំមើលជាប់ជានិច្ច:
- ត្រូវមានទម្រង់ដំណើរការ សំរាប់គ្រប់គ្រងនូវការចូលដល់កន្លែងតម្កល់ទុកនេះ;
- ត្រូវដឹកជញ្ជូន SSAN នៅក្រោមការឃ្លាំមើលជានិច្ចទៅលើបុគ្គលដែលអនុញ្ញាតសំរាប់ការធ្វើដំណើរទាំងស្រុង;
- ត្រូវមានទម្រង់ដំណើរការសំរាប់ឆែកពិនិត្យមើល និងការអនុញ្ញាតឲ្យបុគ្គលដែលប្រើ SSAN ដែលឥតមានអ្នកត្រួតពិនិត្យ រាប់បញ្ចូលទាំង:
  - ជ្រើសតាំងបុគ្គលដែលទទួលខុសត្រូវ (ធម្មតាជាអ្នកកាន់អាជ្ញាប័ណ្ណ) ឲ្យមើលថែទាំគំរោងការសន្តិសុខ;
  - ធ្វើឲ្យជាក់លាក់ថាបុគ្គលដែលប្រើ SSAN ដែលឥតមានអ្នកត្រួតពិនិត្យ ត្រូវតែមានការឆែកពិនិត្យពីប៉ូលិស និងការឆែកពិនិត្យខាងសន្តិសុខ; និង
  - ការបង្ហាត់បង្រៀនដល់អ្នកធ្វើការ អំពីទម្រង់ដំណើរការគំរោងសន្តិសុខ។
- ការរក្សាទុកនូវកំណត់ហេតុទិញ និងប្រើ SSAN ដែលមានទម្រង់ដំណើរការដើម្បីធ្វើឲ្យឃើញថាស៊ីគ្នានឹងចំនួនចូល និងចំនួនចេញ និង
- ទម្រង់ដំណើរការសំរាប់រាយការណ៍ទៅអាជ្ញាធរនូវការបាត់មិនដឹងហេតុ ការលួច ការមានបំណងនឹងលួច ឬហេតុការខាងសន្តិសុខដទៃណាមួយដែលទាក់ទងនឹង SSAN។

**ការកត់សម្គាល់:** សេចក្តីតម្រូវយ៉ាងតិចបំផុតលើផ្នែកសន្តិសុខសំរាប់ការតម្កល់ទុក និងការដឹកជញ្ជូននៃ SSAN ដែលធ្វើឡើងដោយបុគ្គលក្រៅពីអ្នកប្រើអាចមានខុសគ្នា។ ដើម្បីទទួលយកពត៌មាន សូមពិគ្រោះជាមួយអាជ្ញាធរធ្វើបទបញ្ជា។

**តើខ្ញុំត្រូវធ្វើអ្វីខ្លះប្រសិនបើខ្ញុំមានកម្មសិទ្ធិនៅក្នុង ឬឆ្លងកាត់រដ្ឋ ឬដែនដីឯទៀត?**
អ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណដែលមានកម្មសិទ្ធិឆ្លងកាត់ ឬនៅក្នុងព្រំប្រទល់រដ្ឋ/ដែនដីខុសគ្នាឯទៀត ជាដំបូងត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណជាមួយអាជ្ញធរធ្វើបទបញ្ជានៅក្នុងរដ្ឋ ឬដែនដីកន្លែងដែលកាន់កាប់ SSAN ចម្បងរបស់គេតាំងនៅ។ នៅពេលដាក់ពាក្យសុំរបស់ខ្លួន អាជ្ញាធរធ្វើបទបញ្ជានឹងជម្រាបប្រាប់គេអំពីអាជ្ញាធរដទៃទៀតដែលគេត្រូវពិគ្រោះជាមួយ។ ប្រសិនបើមានការតម្រូវឲ្យមានអាជ្ញាប័ណ្ណ បន្ថែមទៀតសំរាប់កន្លែងកាន់កាប់ផ្សេងទៀតអាជ្ញាប័ណ្ណដែលបានចេញឲ្យនៅ កន្លែងកាន់កាប់ចម្បងរបស់លោកអ្នកនឹងត្រូវបានគេលើកយកមកគិតគូរបញ្ចូលដើម្បីកាត់បន្ថយទៅលើការចំណាយ។

**ដើម្បីទទួលយកពត៌មានបន្ថែមទៀត:**
ស្តីអំពីការសំរេចរបស់រដ្ឋាភិបាលនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៤ ដើម្បីបង្កើតជាច្បាប់ប្រើអាមម៉ូនីញ៉ូម ណៃត្រេត សូមយោងទៅគេហទំព័រខាងក្រោមនេះ :
http://www.coag.gov.au/meetings/250604/index.htm.

ចំពោះសម្ភារៈណែនាំសំរាប់ការដឹកជញ្ជូន ការតម្កល់ទុក ការប្រើខាងកសិកម្ម និងការជ្រើសរើសទីកន្លែងនៃគ្រឿងបរិក្ខាប្រើប្រាស់តម្កល់ទុកថ្មីសំរាប់ SSAN សូមបើកមើលគេហទំព័រសន្តិសុខជាតិ www.nationalsecurity.gov.au ហើយបើកមើលទៅតាមការតភ្ជាប់។